# ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា
# Cambodia Public Debt Statistical Bulletin








## លេខ ៤ - Vol. 4

ទិន្នន័យត្រឹមឆមាសទី១ ឆ្នាំ២០១៧ - Data as 1st Semester 2017

រាជធានីភ្នំពេញ, ខែកញ្ញា ឆ្នាំ២០១៧ / Phnom Penh, September 2017

# អារម្ភកថា

រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យវែងឆ្ងាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអនុវត្តយ៉ាងម៉ឺងម៉ាត់ និងគ្មានរាំងនូវគោលការណ៍គន្លឹះចំនួន ០៤ ក្នុងការគ្រប់គ្រងបំណុលសាធារណៈ ដែលរួមមាន៖

១) ត្រូវខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន

២) ត្រូវខ្ចីតែឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់

៣) ត្រូវខ្ចីសម្រាប់តែវិស័យអាទិភាពទ្រទ្រង់ចីរភាពកំណើន និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច

៤) ត្រូវប្រើប្រាស់ឥណទានទាំងនោះ ប្រកបដោយតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព, និងស័ក្តិសិទ្ធិភាពខ្ពស់បំផុត។

អនុលោមតាមមាត្រា៣៤ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងបំណុលសាធារណៈ យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥-២០១៨ និងផែនការសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ - ដំណាក់កាលទី៣ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា ព្រមទាំងបានផ្សព្វផ្សាយនៅលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងបោះពុម្ពសៀវភៅចែកជូនក្រសួង ស្ថាប័នពាក់ព័ន្ធ, ស្ថានទូត, គ្រឹះស្ថានអប់រំ, ដៃគូអភិវឌ្ឍន៍, និងអង្គការក្រៅរដ្ឋាភិបាលនានា ដើម្បីប្រើប្រាស់តាមតម្រូវការជាក់ស្តែង ចំនួន ០៣ លើក រួចមកហើយ។

ក្នុងគោលបំណងបន្តលើកកម្ពស់តម្លាភាព និងគណនេយ្យភាពនៃការគ្រប់គ្រងបំណុលសាធារណៈ ព្រមទាំងធានាបាននូវភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈលើកទី៤ ដែលមានទិន្នន័យត្រឹមឆមាសទី១ ឆ្នាំ២០១៧ ដើម្បីបោះផ្សាយ និងផ្សព្វផ្សាយជាសាធារណៈ។

ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈនេះ ត្រូវបានរៀបរៀង និងបោះផ្សាយជាទៀងទាត់ រៀងរាល់មួយឆមាសម្តង ជាពីរភាសា គឺភាសាខ្មែរ និងភាសាអង់គ្លេស ដោយអនុលោមតាមឧត្តមានុវត្តជាអន្តរជាតិ និងបរិការណ៍ជាក់ស្តែងរបស់កម្ពុជា ដែលមានវិសាលភាពគ្របដណ្តប់លើទិន្នន័យស្តីពី៖ ១) បំណុលសាធារណៈក្រៅប្រទេស; ២) បំណុលសាធារណៈក្នុងប្រទេស; និង ៣) ការផ្តល់ឥណទានរបស់រដ្ឋដល់សហគ្រាសសាធារណៈ, គ្រឹះស្ថានសាធារណៈ, នីតិបុគ្គលសាធារណៈដទៃទៀត, និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកអាន ទិន្នន័យទាំងអស់ត្រូវបានបែងចែកជា ០៤ ក្រុម គឺ៖ ១) ការខ្ចី, ២) ការដកសាច់ប្រាក់, ៣) សេវាបំណុល (ការទូទាត់ជូនឥណទាយក និងការប្រមូលពីឥណទាយិកក្រោមក្របខ័ណ្ឌនៃការផ្តល់ឥណទានរបស់រដ្ឋ), និង ៤) សន្និធិបំណុល ហើយដែលត្រូវបានចាត់ចំណាត់ប្រភេទទៅតាម៖ វិស័យ, ឥណទាយក/ឥណទាយិក, និងរូបិយប័ណ្ណ។

តាមរយៈនៃការចេញផ្សាយចំនួន ០៣ លេខ កន្លងមក ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈនេះ ក៏ត្រូវបានទទួលនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ ពីដៃគូអភិវឌ្ឍន៍ និងជំនាញការអន្តរជាតិមួយចំនួនថាជាព្រឹត្តិបត្រស្ថិតិបំណុលដំបូងគេ ដែលមានព័ត៌មានគ្រប់ជ្រុងជ្រោយ និងរៀបចំបានល្អ ស្របតាមឧត្តមានុវត្តជាអន្តរជាតិ។ ក្នុងនាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ខ្ញុំសូមថ្លែង

អំណរគុណចំពោះដៃគូអភិវឌ្ឍន៍ និងជំនាញការអន្តរជាតិទាំងឡាយ ដែលបានផ្តល់ភាពយុត្តិធម៌ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការគ្រប់គ្រងបំណុលសាធារណៈប្រកបដោយចីរភាព, តម្លាភាព, និងគណនេយ្យភាព។

ខ្ញុំជឿជាក់ថា ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈនេះ ពិតជាអាចបង្កើននូវការយល់ដឹងបន្ថែមជូនសាធារណជន ក៏ដូចជាតួអង្គពាក់ព័ន្ធទាំងឡាយ ជ្រួតជ្រាបកាន់តែច្បាស់អំពីស្ថានភាពបំណុលសាធារណៈជាក់ស្តែងរបស់កម្ពុជា។ ទន្ទឹមនេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ព្រឹត្តិបត្រនេះ នឹងបន្តទទួលបាននូវការគាំទ្រ និងលើកទឹកចិត្តពីអ្នកអានទាំងអស់ ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមស្វាគមន៍នូវរាល់មតិយោបល់ក្នុងន័យស្ថាបនា ដើម្បីកែលម្អព្រឹត្តិបត្រលេខក្រោយៗ ឱ្យកាន់តែប្រសើរថែមទៀត។

ក្នុងករណីមានចម្ងល់ ឬសំណួរផ្សេងៗ សូមទាក់ទងតាមរយៈអ៊ីម៉ែល ddm@mef.gov.kh។

*រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ កញ្ញា ឆ្នាំ២០១៧*

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ**

បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

# មាតិកា

# Table of Contents


ទំព័រ / Page

សេចក្តីសង្ខេបស្តីពីស្ថានភាពបំណុលសាធារណៈកម្ពុជា / ............................................. ១

Executive Summary: Public Debt Situation of Cambodia ............................................. 1

ជំពូក ១៖ ព័ត៌មានទូទៅ / Chapter I: General Information

ក- ពាក្យបំព្រួញ / A- Acronyms and Abbreviations ............................................. ៥ / 5

ខ- វិសាលភាព / B- Coverage ............................................. ៥ / 5

គ- ក្រុម និងចំណាត់ប្រភេទទិន្នន័យ / C- Grouping and Classification ............................................. ៥ / 5

ឃ- ប្រភពទិន្នន័យ / D- Sources ............................................. ៥ / 5

ង- ការបំប្លែងរូបិយប័ណ្ណ / E- Currency Conversion ............................................. ៦ / 6

ច- គោលនយោបាយក្នុងការកែតម្រូវទិន្នន័យ / F- Revision Policy ............................................. ៦ / 6

ឆ- ការបោះផ្សាយ / G- Frequency and Time Lag ............................................. ៧ / 7

ជ- និយមន័យ / H- Definitions ............................................. ៧ / 7

ជំពូក ២៖ តារាងស្ថិតិ / Chapter II: Statistical Tables

តារាងទី១៖ អត្រាប្តូរប្រាក់ / Table 1: Exchange Rates ............................................. ១១ / 11

តារាងទី២៖ សូចនាករបំណុល / Table 2: Debt Indicators ............................................. ១២ / 12

តារាងទី៣៖ សូចនាករថ្លៃ និងហានិភ័យ / Table 3: Cost - Risk Indicators ............................................. ១៣ / 13

តារាងទី៤៖ ការខ្ចី, ការដកសាច់ប្រាក់, ការទូទាត់សេវាបំណុល, និងសន្និធិបំណុល / ............................................. ១៤

Table 4: Borrowing, Disbursement, Debt Service Payment, and Outstanding ............................................. 14

ផ្នែកទី ១៖ បំណុលសាធារណៈក្រៅប្រទេស / Part 1: Public External Debt

១.១. ការខ្ចី / 1.1. Borrowing

តារាងទី៥៖ ការខ្ចីតាមវិស័យ / Table 5: Borrowing by Sector ............................................. ១៥ / 15

តារាងទី៦៖ ការខ្ចីតាមឥណទាយក / Table 6: Borrowing by Creditor ............................................. ១៦ / 16

តារាងទី៧៖ ការខ្ចីតាមរូបិយប័ណ្ណ / Table 7: Borrowing by Currency ............................................. ១៧ / 17

១.២. ការដកសាច់ប្រាក់ / 1.2. Disbursement

តារាងទី៨៖ ការដកសាច់ប្រាក់តាមវិស័យ / Table 8: Disbursement by Sector ............................................. ១៨ / 18

តារាងទី៩៖ ការដកសាច់ប្រាក់តាមឥណទាយក / Table 9: Disbursement by Creditor ............................................. ១៩ / 19

តារាងទី១០៖ ការដកសាច់ប្រាក់តាមរូបិយប័ណ្ណ / Table 10: Disbursement by Currency ............................................. ២០ / 20

១.៣. ការទូទាត់សេវាបំណុល / 1.3. Debt Service Payment

តារាងទី១១៖ ការទូទាត់សេវាបំណុលតាមឥណទាយក / ............................................. ២១

Table 11: Debt Service Payment by Creditor ............................................. 21

តារាងទី១២៖ ការទូទាត់សេវាបំណុលតាមរូបិយប័ណ្ណ / ............................................. ២២

Table 12: Debt Service Payment by Currency ............................................. 22

១.៤. សន្និធិបំណុល / 1.4. Outstanding

តារាងទី១៣៖ សន្និធិបំណុលតាមឥណទាយក / Table 13: Outstanding by Creditor ............................................. ២៣ / 23

តារាងទី១៤៖ សន្និធិបំណុលតាមរូបិយប័ណ្ណ / Table 14: Outstanding by Currency ............................................. ២៤ / 24

ផ្នែកទី ២៖ បំណុលសាធារណៈក្នុងប្រទេស / Part 2: Public Domestic Debt

តារាងទី១៥៖ ការទូទាត់សេវាបំណុល និងសន្និធិបំណុលសាធារណៈក្នុងប្រទេស / ........................................ ២៥

Table 15: Public Domestic Debt Service Payment and Outstanding ............................................ 25

ផ្នែកទី ៣៖ ការផ្តល់ឥណទានរបស់រដ្ឋ / Part 3: Government Lending and On-lending

តារាងទី១៦៖ ការផ្តល់ឥណទាន, ការដកសាច់ប្រាក់, ការប្រមូលសេវាបំណុល, និងសន្និធិបំណុល /.................. ២៦

Table 16: Lending and On-lending, Disbursement, Debt Service Collection, and Outstanding ..... 26

៣.១. ការផ្តល់ឥណទាន / 3.1. Lending and On-lending

តារាងទី១៧៖ ការផ្តល់ឥណទានតាមវិស័យ / Table 17: Lending and On-lending by Sector............. ២៧ / 27

តារាងទី១៨៖ ការផ្តល់ឥណទានតាមឥណទាយិក / Table 18: Lending and On-lending by Debtor......... ២៨ / 28

តារាងទី១៩៖ ការផ្តល់ឥណទានតាមរូបិយប័ណ្ណ / Table 19: Lending and On-lending by Currency ....... ២៩ / 29

៣.២. ការដកសាច់ប្រាក់ / 3.2. Disbursement

តារាងទី២០៖ ការដកសាច់ប្រាក់ក្នុងក្របខ័ណ្ឌការផ្តល់ឥណទានរបស់រដ្ឋតាមវិស័យ / .................................... ៣០

Table 20: Lending and On-lending Disbursement by Sector ........................................................ 30

តារាងទី២១៖ ការដកសាច់ប្រាក់តាមឥណទាយិក / ................................................................................ ៣១

Table 21: Disbursement by Debtor ............................................................................................ 31

តារាងទី២២៖ ការដកសាច់ប្រាក់ក្នុងក្របខ័ណ្ឌការផ្តល់ឥណទានរបស់រដ្ឋតាមរូបិយប័ណ្ណ / .............................. ៣២

Table 22: Lending and On-lending Disbursement by Currency .................................................. 32

៣.៣. ការប្រមូលសេវាបំណុល / 3.3. Debt Service Collection

តារាងទី២៣៖ ការប្រមូលសេវាបំណុលតាមឥណទាយិក / ........................................................................ ៣៣

Table 23: Debt Service Collection by Debtor ............................................................................. 33

៣.៤. សន្និធិបំណុល / 3.4. Outstanding

តារាងទី២៤៖ សន្និធិបំណុលក្នុងក្របខ័ណ្ឌការផ្តល់ឥណទានរបស់រដ្ឋតាមឥណទាយិក / ................................ ៣៤

Table 24: Lending and On-lending Outstanding by Debtor .......................................................... 34

តារាងទី២៥៖ សន្និធិបំណុលក្នុងក្របខ័ណ្ឌការផ្តល់ឥណទានរបស់រដ្ឋតាមរូបិយប័ណ្ណ /................................... ៣៥

Table 25: Lending and On-lending Outstanding by Currency ..................................................... 35

ផ្នែកទី ៤៖ ការព្យាករណ៍ / Part 4: Projections

តារាងទី២៦៖ ព្យាករណ៍ការខ្ចីក្រៅប្រទេស, ការដកសាច់ប្រាក់, ការទូទាត់សេវាបំណុល, និងសន្និធិបំណុល /....... ៣៦

Table 26: Projections of External Borrowing, Disbursement, Debt Service Payment, and Outstanding ...... 36

តារាងទី២៧៖ ព្យាករណ៍ការដកសាច់ប្រាក់ និងការប្រមូលសេវាបំណុលក្នុងក្របខ័ណ្ឌការផ្តល់ឥណទានរបស់រដ្ឋ /..... ៣៧

Table 27: Projections of Lending and On-lending Disbursement and Debt Service Collection ...... 37

តារាងទី២៨៖ ព្យាករណ៍ការទូទាត់សេវាបំណុលប្រចាំខែ តាមរូបិយប័ណ្ណ ក្នុងឆ្នាំ២០១៧ / ............................... ៣៨

Table 28: Projections of Monthly Debt Service Payment by Currency in 2017 .............................. 38

តារាងទី២៩៖ ព្យាករណ៍ការទូទាត់សេវាបំណុលប្រចាំខែ សម្រាប់ឆ្នាំ២០១៧-២០២១ /.................................. ៣៩

Table 29: Projections of Monthly Debt Service Payment for 2017-2021 ........................................ 39

ជំពូក ៣៖ ក្រាហ្វ / Chapter III: Graphs


ក្រាហ្វទី១៖ ការខ្ចីក្រៅប្រទេស (ប្រចាំឆ្នាំ-ឆមាស និងសរុបត្រឹមឆមាសទី១ ឆ្នាំ២០១៧) /............................ ៤០

Graph 1: External Borrowing (Annual-Semiannual and Accumulated as of S1 2017) ................40

ក្រាហ្វទី២៖ ការដកសាច់ប្រាក់ (ប្រចាំឆ្នាំ-ឆមាស និងសរុបត្រឹមឆមាសទី១ ឆ្នាំ២០១៧) /............................ ៤១

Graph 2: Disbursement (Annual-Semiannual and Accumulated as of S1 2017) ........................ 41

ក្រាហ្វទី៣៖ ការទូទាត់សេវាបំណុលក្រៅប្រទេស (ប្រចាំឆ្នាំ-ឆមាស និងសរុបត្រឹមឆមាសទី១ ឆ្នាំ២០១៧) /..... ៤២

Graph 3: External Debt Service Payment (Annual-Semiannual and Accumulated as of S1 2017) 42

ក្រាហ្វទី៤៖ សន្និធិបំណុលសាធារណៈ / ................................................................................៤៣

Graph 4: Public Debt Outstanding................................................................................ 43

ក្រាហ្វទី៥៖ ការវិភាគចីរភាពបំណុល /................................................................................ ៤៤

Graph 5: Debt Sustainability Analysis (DSA) ....................................................................44

ក្រាហ្វទី៦៖ ការផ្តល់ឥណទានរបស់រដ្ឋ (ប្រចាំឆ្នាំ-ឆមាស និងសរុបត្រឹមឆមាសទី១ ឆ្នាំ២០១៧) / ................. ៤៥

Graph 6: Government Lending and On-lending (Annual-Semiannual and Accumulated as of S1 2017) 45

ក្រាហ្វទី៧៖ ការដកសាច់ប្រាក់ពីរដ្ឋ (ប្រចាំឆ្នាំ-ឆមាស និងសរុបត្រឹមឆមាសទី១ ឆ្នាំ២០១៧) /...................... ៤៦

Graph 7: Lending and On-lending Disbursement (Annual-Semiannual and Accumulated as of S1 2017)46

ក្រាហ្វទី៨៖ ការប្រមូលសេវាបំណុល និងសន្និធិបំណុលក្នុងក្របខ័ណ្ឌការផ្តល់ឥណទានរបស់រដ្ឋ /..................៤៧

Graph 8: Lending and On-lending Debt Service Collection and Outstanding................................47

ក្រាហ្វទី៩៖ ព្យាករណ៍ការទូទាត់សេវាបំណុលប្រចាំខែ សម្រាប់ឆ្នាំ២០១៧-២០២១ /.................................. ៤៨

Graph 9: Projections of Monthly Debt Service Payment for 2017-2021 .......................................48

# សេចក្តីសង្ខេបស្តីពី
# ស្ថានភាពបំណុលសាធារណៈកម្ពុជា

## Executive Summary:

## Public Debt Situation of Cambodia

# ស្ថានភាពបំណុលសាធារណៈកម្ពុជា ត្រឹមឆមាសទី១ ឆ្នាំ២០១៧

## Executive Summary: Public Debt Situation of Cambodia as of 1st Semester 2017

## I. បំណុលសាធារណៈក្រៅប្រទេស

### 1.1 ការខ្ចី

នៅក្នុងឆមាសទី១ ឆ្នាំ២០១៧ រាជរដ្ឋាភិបាលបានចុះកិច្ចព្រមព្រៀងខ្ចីឥណទានសម្បទាន ជាមួយដៃគូអភិវឌ្ឍន៍នានា សរុបចំនួនប្រមាណ ***៧៣២,០៦ លានដុល្លារអាមេរិក*** ឬប្រមាណ ***៥២៣,៨១ លានអេសដេអ៊ែរ*** ស្មើនឹង ***៧៤,៨៣%*** នៃពិដានដែលច្បាប់អនុញ្ញាត ***(៧០០ លានអេសដេអ៊ែរ)*** ក្នុងនោះ÷ ក្របខ័ណ្ឌទ្វេភាគី មានចំនួនប្រមាណ ***៧៨,០៩%*** ត្រូវនឹងប្រមាណ ***៥៧១,៦៦ លានដុល្លារអាមេរិក*** និងក្របខ័ណ្ឌពហុភាគី មានចំនួនប្រមាណ ***២១,៩១%*** ត្រូវនឹងប្រមាណ ***១៦០,៤០ លានដុល្លារអាមេរិក***។ គោលដៅនៃការខ្ចីឥណទានសម្បទានទាំងនេះ គឺសុទ្ធតែសម្រាប់ហិរញ្ញប្បទានលើគម្រោងវិនិយោគសាធារណៈក្នុងវិស័យអាទិភាពរបស់រាជរដ្ឋាភិបាល សំដៅរួមចំណែកទ្រទ្រង់ចីរភាពនៃកំណើនរយៈពេលវែង និងបង្កើនផលិតភាពសេដ្ឋកិច្ច ឬផលិតភាពផលិតកម្ម ដែលក្នុងនោះ វិស័យហេដ្ឋារចនាសម្ព័ន្ធ គ្របដណ្តប់ប្រមាណ ***៩៤,៣៧%*** និងវិស័យអាទិភាពផ្សេងទៀតប្រមាណ ***៥,៦៣%***។ ជារួម ឥណទានទាំងនេះ សុទ្ធសឹងជាឥណទានដែលមានកម្រិតសម្បទានខ្ពស់ ដោយមានធាតុអំណោយជាមធ្យម ***៥២,១០%***។

បើគិតចាប់ពីឆ្នាំ១៩៩៣ រហូតមកដល់ឆមាសទី១ ឆ្នាំ២០១៧ រាជរដ្ឋាភិបាលបានចុះកិច្ចព្រមព្រៀងខ្ចីឥណទានសម្បទានជាមួយដៃគូអភិវឌ្ឍន៍នានា សរុបចំនួនប្រមាណ ***៩ ២៩៥,២៦ លានដុល្លារអាមេរិក*** ក្នុងនោះ÷ វិស័យហេដ្ឋារចនាសម្ព័ន្ធគ្របដណ្តប់ប្រមាណ ***៨៧,១២%*** និងវិស័យអាទិភាពផ្សេងទៀត ប្រមាណ ***១២,៨៨%***។

### 1.2 ការដកសាច់ប្រាក់

នៅក្នុងឆមាសទី១ ឆ្នាំ២០១៧ រាជរដ្ឋាភិបាលបានដកសាច់ប្រាក់ ពីដៃគូអភិវឌ្ឍន៍យកមកប្រើប្រាស់ជាក់ស្តែងសរុបចំនួនប្រមាណ ***៣១៣,២៨ លានដុល្លារអាមេរិក*** ក្នុងនោះ÷ ក្របខ័ណ្ឌទ្វេភាគី មានចំនួនប្រមាណ ***៦៨,៥៣%*** ត្រូវនឹង

## I. Public External Debt

### 1.1 Borrowing

In 1st Semester 2017, the Royal Government of Cambodia (RGC) has signed concessional loan agreements with Development Partners (DPs) in total of **USD 732.06 million** (equivalent to **SDR 523.81 million**) accounting for **74.83%** of the debt ceiling of **SDR 700 million**, in which **78.09%** or **USD 571.66 million** with bilateral DPs and **21.91%** or **USD 160.40 million** with multilateral DPs. The purpose of the borrowing is to finance public investment projects in the priority sectors which support sustainable long-term economic growth and increase economic productivity/production capacity; the infrastructure sector accounts for **94.37%**, while **5.63%** is attributed to other priority sectors. Generally, the loans are highly concessional with an average grant element of **52.10%**.

Accumulatively, from 1993 to 1st Semester 2017, the RGC has signed concessional loan agreements with DPs **USD 9,295.26 million** in which **87.12%** and **12.88%** covered by infrastructure and other priority sectors respectively.

### 1.2 Disbursement

In 1st Semester 2017, the RGC has disbursed **USD 313.28 million** from the DPs in which **68.53%** or **USD 214.68 million** from the bilateral DPs and **31.47%** or **USD 98.60 million**

ប្រមាណ ***២១៤,៦៨ លានដុល្លារអាមេរិក*** និងក្របខ័ណ្ឌពហុភាគី មានចំនួនប្រមាណ ***៣១,៤៧%*** ត្រូវនឹងប្រមាណ ***៩៨,៦០ លានដុល្លារអាមេរិក***។

បើគិតចាប់ពីឆ្នាំ១៩៩៣ រហូតមកដល់ឆមាសទី១ ឆ្នាំ២០១៧ រាជរដ្ឋាភិបាលបានដកសាច់ប្រាក់ពីដៃគូអភិវឌ្ឍន៍យកមកប្រើប្រាស់ជាក់ស្តែងសរុបចំនួនប្រមាណ ***៦ ២៤៤,៩២ លានដុល្លារអាមេរិក*** ស្មើនឹងប្រមាណ ***៦៧,១៨%*** នៃទំហំឥណទានសម្បទានសរុប ដែលបានចុះកិច្ចព្រមព្រៀងខ្ចីឥណទានសម្បទានខាងលើ ក្នុងនោះ÷ ***៨៥,៩០%*** ត្រូវបានប្រើប្រាស់ដើម្បីហិរញ្ញប្បទានលើគម្រោងវិនិយោគសាធារណៈក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ និង ***១៤,១០%*** ទៀត ក្នុងវិស័យអាទិភាពផ្សេងទៀត។

from the multilateral DPs.

Accumulatively, from 1993 to 1st semester 2017, the RGC has disbursed **USD 6,244.92 million** from DPs accounting for **67.18%** of the total borrowing in which **85.90%** and **14.10%** covered by infrastructure and other priority sectors respectively.

### 1.3 ការទូទាត់សេវាបំណុល

នៅក្នុងឆមាសទី១ ឆ្នាំ២០១៧ រាជរដ្ឋាភិបាលបានទូទាត់សេវាបំណុលជូនដៃគូអភិវឌ្ឍន៍សរុបចំនួន ***១០០,០២ លានដុល្លារអាមេរិក*** ក្នុងនោះ÷ ក្របខ័ណ្ឌបំណុលសាធារណៈក្នុងប្រទេស មានចំនួនប្រមាណ ***០,០៤%*** ត្រូវនឹងប្រមាណ ***០,០៤ លានដុល្លារអាមេរិក*** (ប្រាក់ដើម ***០ ដុល្លារអាមេរិក*** និងការប្រាក់ ***០,០៤ លានដុល្លារអាមេរិក***) និងក្របខ័ណ្ឌបំណុលសាធារណៈក្រៅប្រទេស មានចំនួនប្រមាណ ***៩៩,៩៦%*** ត្រូវនឹងប្រមាណ ***៩៩,៩៨ លានដុល្លារអាមេរិក*** (ប្រាក់ដើម ***៦៣,១៧ លានដុល្លារអាមេរិក*** និងការប្រាក់និងកម្រៃផ្សេងៗ ***៣៦,៨១ លានដុល្លារអាមេរិក***)។

បើគិតចាប់ពីឆ្នាំ១៩៩៣ រហូតមកដល់ឆមាសទី១ ឆ្នាំ២០១៧ រាជរដ្ឋាភិបាលបានទូទាត់សេវាបំណុលជូនដៃគូអភិវឌ្ឍន៍សរុបចំនួន ***១ ០១០,៧៣ លានដុល្លារអាមេរិក*** ក្នុងនោះ÷ ក្របខ័ណ្ឌបំណុលសាធារណៈក្នុងប្រទេស មានចំនួនប្រមាណ ***១,៦៥%*** ត្រូវនឹងប្រមាណ ***១៦,៧២ លានដុល្លារអាមេរិក*** (ប្រាក់ដើម ***១៣,៨៣ លានដុល្លារអាមេរិក*** និងការប្រាក់ ***២,៩០ លានដុល្លារអាមេរិក***) និងក្របខ័ណ្ឌបំណុលសាធារណៈក្រៅប្រទេស មានចំនួនប្រមាណ ***៩៨,៣៥%*** ត្រូវនឹងប្រមាណ ***៩៩៤,០១ លានដុល្លារអាមេរិក*** (ប្រាក់ដើម ***៥៦២,០២ លានដុល្លារអាមេរិក*** និងការប្រាក់និងកម្រៃផ្សេងៗ

### 1.3 Debt Service Payment

In 1st Semester 2017, the RGC has made debt service payment to DPs in amount of **USD 100.02 million** in which **0.04%** or **USD 0.04 million** (principal **nil**, interest **USD 0.04 million**) is public domestic debt and **99.96%** or **USD 99.98 million** (principal **USD 63.17 million**, interest and other fees **USD 36.81 million**) is public external debt.

Accumulatively, from 1993 to 1st Semester 2017, the RGC has made debt service payment to DPs **USD 1,010.73 million** in which **1.65%** or **USD 16.72 million** (principal **USD 13.83 million**, interest **USD 2.90 million**) is public domestic debt and **98.35%** or **USD 994.01 million** (principal **USD 562.02 million**, interest and other fees **USD 431.99 million**) is public external debt.

*៤៣១,៩៩ លានដុល្លារអាមេរិក*។

### 1.4 សន្និធិបំណុល

គិតត្រឹមឆមាសទី១ ឆ្នាំ២០១៧ កម្ពុជាមានសន្និធិបំណុលសាធារណៈសរុបចំនួនប្រមាណ ***៦ ២៣៥,៩៥ លានដុល្លារអាមេរិក*** ក្នុងនោះ÷ ក្របខ័ណ្ឌបំណុលសាធារណៈក្នុងប្រទេស មានចំនួនប្រមាណ ***០,០៤%*** ត្រូវនឹងប្រមាណ ***២,៧៤ លានដុល្លារអាមេរិក*** និងក្របខ័ណ្ឌបំណុលសាធារណៈក្រៅប្រទេសមានចំនួនប្រមាណ ***៩៩,៩៦%*** ត្រូវនឹងប្រមាណ ***៦ ២៣៣,២១ លានដុល្លារអាមេរិក***។

### 1.5 អនុបាតបំណុល

តាមការវិភាគចីរភាពបំណុលបង្ហាញថា អនុបាតបំណុលសំខាន់ៗទាំងប្រាំសុទ្ធតែស្ថិតក្រោមអនុបាតគោល ក្នុងនោះ÷ ១) អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេសធៀបនឹង ផសស មានត្រឹមកម្រិត ***២២,៨%*** ធៀបនឹងអនុបាតគោលកម្រិត ***៤០%***, ២) អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេសធៀបនឹងការនាំចេញ មានត្រឹមកម្រិត ***៣០,៨%*** ធៀបនឹងអនុបាតគោលកម្រិត ***១៥០%***, ៣) អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេសធៀបនឹងចំណូលថវិកាជាតិ មានត្រឹមកម្រិត ***១៣៥,៨%*** ធៀបនឹងអនុបាតគោលកម្រិត ***២៥០%***, ៤) អនុបាតសេវាបំណុលធៀបនឹងការនាំចេញមានត្រឹមកម្រិត ***១,៦%*** ធៀបនឹងអនុបាតគោល ***២០%***, និង ៥) អនុបាតសេវាបំណុលធៀបនឹងចំណូលថវិកាជាតិ មានត្រឹមកម្រិត ***៧,០%*** ធៀបនឹងអនុបាតគោល ***២០%***។

ជាសន្និដ្ឋាន ដោយផ្អែកតាមបទដ្ឋានបច្ចេកទេសអន្តរជាតិ លទ្ធផលខាងលើនេះ បញ្ជាក់ថា ស្ថានភាពបំណុលសាធារណៈកម្ពុជាបច្ចុប្បន្នមាន ***"ចីរភាព"*** និង ***"ហានិភ័យកម្រិតទាប"***។

## II. ការផ្តល់ឥណទានរបស់រដ្ឋ

### 2.1 ការផ្តល់ឥណទាន

នៅក្នុងឆមាសទី១ ឆ្នាំ២០១៧ រាជរដ្ឋាភិបាលបានចុះកិច្ចព្រមព្រៀងផ្តល់ឥណទាន ជាមួយឥណទាយិក សរុបចំនួនប្រមាណ ***១១,២៩ លានដុល្លារអាមេរិក*** ។

### 1.4 Outstanding

As of 1st Semester 2017, the RGC has a total public debt outstanding of **USD 6,235.95 million** in which **0.04%** or **USD 2.74 million** is public domestic debt and **99.96%** or **USD 6,233.21 million** is public external debt.

### 1.5 Debt Ratios

The result of Debt Sustainability Analysis (DSA) showed that all the five key debt indicators are well below the respective indicative thresholds in which 1) PV of public external debt to GDP **22.8%** (threshold **40%**), 2) PV of public external debt to exports **30.8%** (threshold **150%**), 3) PV of public external debt to revenue **135.8%** (threshold **250%**), 4) Debt service to exports **1.6%** (threshold **20%**), and 5) Debt service to revenue **7.0%** (threshold **20%**).

Based on the international best practice, therefore, the Cambodia's public debt remains **"sustainable"** and **"low risk"** of debt distress.

## II. Government Lending and On-lending

### 2.1 Lending and On-lending

In 1st Semester 2017, the RGC has signed lending and on-lending agreements with debtors in total of **USD 11.29 million.**

បើគិតចាប់ពីឆ្នាំ១៩៩៣ រហូតមកដល់ឆមាសទី១ ឆ្នាំ២០១៧ រាជរដ្ឋាភិបាលបានចុះកិច្ចព្រមព្រៀងផ្តល់ឥណទានជាមួយឥណទាយិក សរុបចំនួនប្រមាណ ***១ ៥៥២,៦៩ លានដុល្លារអាមេរិក*** ក្នុងនោះ÷ វិស័យហេដ្ឋារចនាសម្ព័ន្ធគ្របដណ្តប់ប្រមាណ ***៩៨,៦៨%*** និងវិស័យអាទិភាពផ្សេងទៀត ប្រមាណ ***១,៣២%*** ។

Accumulatively, from 1993 to 1st semester of 2017, the RGC has signed lending and on-lending agreements with debtors **USD 1,552.69 million** in which **98.68%** and **1.32%** covered by infrastructure and other priority sectors respectively.

## 2.2 ការដកសាច់ប្រាក់

នៅក្នុងឆមាសទី១ ឆ្នាំ២០១៧ ឥណទាយិកបានដកសាច់ប្រាក់យកទៅប្រើប្រាស់ជាក់ស្តែងសរុបចំនួនប្រមាណ ***១៨,៥៥ លានដុល្លារអាមេរិក***។

បើគិតចាប់ពីឆ្នាំ១៩៩៣ រហូតមកដល់ឆមាសទី១ ឆ្នាំ២០១៧ ឥណទាយិកបានដកសាច់ប្រាក់យកទៅប្រើប្រាស់ជាក់ស្តែងសរុបចំនួនប្រមាណ ***១ ០៧២,២២ លានដុល្លារអាមេរិក*** ស្មើនឹងប្រមាណ ***៦៩,០៥%*** នៃការផ្តល់ឥណទានដែលបានចុះកិច្ចព្រមព្រៀងខាងលើ ក្នុងនោះ÷ ***៩៨,០៩%*** ត្រូវបានប្រើប្រាស់ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ និង ***១,៩១%*** ទៀត ក្នុងវិស័យអាទិភាពផ្សេងទៀត។

## 2.2 Disbursement

In 1st Semester 2017, **USD 18.55 million** has been disbursed to debtors.

Accumulatively, from 1993 to 1st semester 2017, **USD 1,072.22 million** accounting for **69.05%** of the total lending and on-lending has been disbursed in which **98.09%** and **1.91%** covered by infrastructure and other priority sectors respectively.

## 2.3 ការប្រមូលសេវាបំណុល

នៅក្នុងឆមាសទី១ ឆ្នាំ២០១៧ រាជរដ្ឋាភិបាលបានប្រមូលសេវាបំណុលពីឥណទាយិកសរុបចំនួន ***៣០,២៦ លានដុល្លារអាមេរិក*** ក្នុងនោះ÷ ប្រាក់ដើមមានចំនួនប្រមាណ ***១៨,៦៤ លានដុល្លារអាមេរិក*** និងការប្រាក់និងកម្រៃផ្សេងៗ ***១១,៦២ លានដុល្លារអាមេរិក***។

បើគិតចាប់ពីឆ្នាំ១៩៩៣ រហូតមកដល់ឆមាសទី១ ឆ្នាំ២០១៧ រាជរដ្ឋាភិបាលបានប្រមូលសេវាបំណុលពីឥណទាយិកសរុបចំនួន ***៣៧៨,៨២ លានដុល្លារអាមេរិក*** ក្នុងនោះ÷ ប្រាក់ដើមមានចំនួនប្រមាណ ***២១៩,៨៦ លានដុល្លារអាមេរិក*** និងការប្រាក់និងកម្រៃផ្សេងៗ ***១៥៨,៩៦ លានដុល្លារអាមេរិក***។

## 2.3 Debt Service Collection

In 1st Semester 2017, the RGC has collected debt service from the debtors in amount of **USD 30.26 million** in which **USD 18.64 million** is principal and **USD 11.62 million** is interest and other fees.

Accumulatively, from 1993 to 1st semester 2017, the RGC has collected debt service from the debtors **USD 378.82 million** in which **USD 219.86 million** is principal and **USD 158.96 million** is interest and other fees.

## 2.4 សន្និធិបំណុល

គិតត្រឹមឆមាសទី១ ឆ្នាំ២០១៧ សន្និធិបំណុលក្នុងក្របខ័ណ្ឌការផ្តល់ឥណទានរបស់រដ្ឋសរុបមានចំនួនប្រមាណ ***៨៥២,៣៦ លានដុល្លារអាមេរិក*** ។

## 2.4 Outstanding

As of 1st Semester 2017, the outstanding of lending and on-lending accounts for **USD 852.36 million.**

# ជំពូក ១

# ព័ត៌មានទូទៅ

# Chapter I

# General Information

## ក- ពាក្យបំព្រួញ / A- Acronyms and Abbreviations

| | | |
|---|---|---|
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| CNY | Chinese Yuan Renminbi | យ័នចិន |
| EUR | Euro | អឺរ៉ូ |
| IFAD | International Fund for Agricultural Development | មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម |
| JPY | Japanese Yen | យ៉េនជប៉ុន |
| KHR | Khmer Riel | រៀលខ្មែរ |
| KRW | Korean Won | វ៉ុនកូរ៉េ |
| MYR | Malaysian Ringgit | រីងហ្គីតម៉ាឡេស៊ី |
| NDF | Nordic Development Fund | មូលនិធិអភិវឌ្ឍន៍ណ័រឌីក |
| OFID | OPEC Fund for International Development | មូលនិធិអូប៉ិចសម្រាប់ការអភិវឌ្ឍអន្តរជាតិ |
| SDR | Special Drawing Rights | អេសដេអ៊ែរ |
| THB | Thai Baht | បាតថៃ |
| USD | United States Dollar | ដុល្លារអាមេរិក |
| WB | World Bank | ធនាគារពិភពលោក |

## ខ- វិសាលភាព

ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈនេះ មានវិសាលភាពគ្របដណ្តប់លើទិន្នន័យស្តីពី៖ ១) បំណុលសាធារណៈក្រៅប្រទេស, ២) បំណុលសាធារណៈក្នុងប្រទេស, និង ៣) ការផ្តល់ឥណទានរបស់រដ្ឋ។

## B. Coverage

This public debt statistical bulletin covers data on: 1) Public External Debt, 2) Public Domestic Debt, and 3) Government Lending and On-lending.

## គ- ក្រុម និងចំណាត់ប្រភេទទិន្នន័យ

ទិន្នន័យក្នុងព្រឹត្តិបត្រនេះ ត្រូវបានបែងចែកជា ០៤ ក្រុម គឺ៖ ១) ការខ្ចី, ២) ការដកសាច់ប្រាក់, ៣) សេវាបំណុល (ការទូទាត់ និងការប្រមូល), និង ៤) សន្និធិបំណុល។

បន្ថែមលើនេះ ទិន្នន័យត្រូវបានចាត់ចំណាត់ប្រភេទទៅតាម៖ ១) វិស័យ, ២) ឥណទាយក/ឥណទាយិក, និង ៣) រូបិយប័ណ្ណ។

## C. Grouping and Classification

Data in this bulletin are grouped in 04 categories: 1) Borrowing, 2) Disbursement, 3) Debt Service (Payment and Collection), and 4) Outstanding.

Furthermore, the data are classified by: 1) Sector, 2) Creditor/Debtor, and 3) Currency.

## ឃ- ប្រភពទិន្នន័យ

ទិន្នន័យ សម្រាប់ប្រើជាមូលដ្ឋានក្នុងការរៀបចំព្រឹត្តិបត្រនេះ មានប្រភព ដូចខាងក្រោម៖

- ទិន្នន័យបំណុល៖ អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
- ទិន្នន័យម៉ាក្រូសេដ្ឋកិច្ច៖ អគ្គនាយកដ្ឋានគោល

## D. Sources

The sources of data used for preparing this bulletin are as below:

- Debt data: General Department of International Cooperation and Debt Management, Ministry of Economy and Finance.

នយោបាយ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
– ទិន្នន័យអត្រាប្តូរប្រាក់៖ ធនាគារជាតិនៃកម្ពុជា។

- Macro-economic data: General Department of Policy, Ministry of Economy and Finance.
- Exchange rates data: National Bank of Cambodia.

## ង- ការបំប្លែងរូបិយប័ណ្ណ

ការបំប្លែងរូបិយប័ណ្ណ ត្រូវបានអនុវត្តតាមវិធីសាស្ត្រជាបទដ្ឋានបច្ចេកទេសអន្តរជាតិ ដូចខាងក្រោម៖

– ការខ្ចី៖ គិតតាមអត្រាប្តូរប្រាក់នៅថ្ងៃចុងគ្រា (ថ្ងៃទី៣០ ខែមិថុនា ឬថ្ងៃទី៣១ ខែធ្នូ)។
– ការដកសាច់ប្រាក់៖
  • ប្រចាំឆមាស/ឆ្នាំ៖ គិតតាមអត្រាប្តូរប្រាក់នៅថ្ងៃដកសាច់ប្រាក់ជាក់ស្តែង។
  • សរុប៖ គិតតាមអត្រាប្តូរប្រាក់នៅថ្ងៃចុងគ្រា។
– សេវាបំណុល៖
  • ប្រចាំឆមាស/ឆ្នាំ៖ គិតតាមអត្រាប្តូរប្រាក់នៅថ្ងៃទូទាត់/ប្រមូល សេវាបំណុលជាក់ស្តែង។
  • សរុប៖ គិតតាមអត្រាប្តូរប្រាក់នៅថ្ងៃចុងគ្រា។
– សន្និធិបំណុល៖ គិតតាមអត្រាប្តូរប្រាក់នៅថ្ងៃចុងគ្រា។
– ការព្យាករណ៍៖ គិតតាមអត្រាប្តូរប្រាក់នៅថ្ងៃចុងគ្រា។

## E. Currency Conversion

The international best practice approach has been applied for the currency conversion as follows:

- Borrowing: converted by the exchange rates at end-period (on 30 June or 31 December).
- Disbursement:
  • Semi-annual/Annual: converted by exchange rates on actual disbursement date.
  • Accumulated: converted by the exchange rates at end-period.
- Debt Service:
  • Semi-annual/Annual: converted by exchange rates on actual debt service payment/collection date.
  • Accumulated: converted by the exchange rates at end-period.
- Outstanding: converted by the exchange rates at end-period.
- Projections: converted by the exchange rates at end-period.

## ច- គោលនយោបាយក្នុងការកែតម្រូវទិន្នន័យ

តួលេខមួយចំនួននៅក្នុងព្រឹត្តិបត្រនេះ ត្រូវបានកែតម្រូវពីតួលេខដែលបានរាយការណ៍កន្លងមក ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយក៏អាចនឹងត្រូវបានកែតម្រូវនៅក្នុងការបោះផ្សាយលើកក្រោយផងដែរ។ តួលេខទាំងឡាយណាដែលមានគូសបន្ទាត់ពីក្រោម បញ្ជាក់ថាជាតួលេខដែលបានកែតម្រូវ។

## F. Revision Policy

Some figures in this bulletin have been revised from the figures previously reported by the Ministry of Economy and Finance and might also be revised in the next edition. The figures with underline are the revised figures.

## ឆ- ការបោះផ្សាយ

ព្រឹត្តិបត្រនេះ នឹងត្រូវបានបោះផ្សាយមួយឆមាសម្តង ក្នុងរយៈពេលមិនលើសពី ០៣ ខែ បន្ទាប់ពីដំណាច់ឆមាសនីមួយៗ។

## G. Frequency and Time Lag

The bulletin will be published on a semi-annual basis within time lag of 03 months

## ជ- និយមន័យ

និយមន័យនៃវាក្យស័ព្ទគន្លឹះៗ ដែលប្រើប្រាស់ក្នុងព្រឹត្តិបត្រនេះ មានដូចខាងក្រោម៖

- **បំណុលសាធារណៈក្រៅប្រទេស៖** សំដៅដល់បំណុលក្រៅប្រទេសរបស់រដ្ឋ ដែលកើតឡើងស្របតាមច្បាប់អនុញ្ញាត ដោយមិនគិតបញ្ចូលបំណុលដែលពុំមានការធានាពីរដ្ឋ។ ក្នុងបរិការណ៍កម្ពុជាបច្ចុប្បន្ន បំណុលនេះមានតែ ការខ្ចីឥណទានសម្បទានពីដៃគូអភិវឌ្ឍន៍ ទ្វេភាគី និងពហុភាគីក្រៅប្រទេស ប៉ុណ្ណោះ។ ទោះជាយ៉ាងនេះក្តី ទៅថ្ងៃមុខ បំណុលនេះ អាចនឹងរួមបញ្ចូលផងដែរនូវឧបករណ៍បំណុលផ្សេងទៀត ដូចជា សញ្ញាប័ណ្ណរដ្ឋអធិបតេយ្យជាដើម ក្នុងករណីរាជរដ្ឋាភិបាលសម្រេចធ្វើការបោះផ្សាយ។

- **បំណុលសាធារណៈក្នុងប្រទេស៖** សំដៅដល់បំណុលក្នុងប្រទេសរបស់រដ្ឋ ដែលកើតឡើងស្របតាមច្បាប់អនុញ្ញាត ដោយមិនគិតបញ្ចូលនូវបំណុលដែលពុំមានការធានាពីរដ្ឋ។ ក្នុងបរិការណ៍កម្ពុជាបច្ចុប្បន្ន បំណុលនេះ មានតែសញ្ញាប័ណ្ណរដ្ឋមិនអាចជួញដូរបាន ដែលរាជរដ្ឋាភិបាលបានបោះផ្សាយ ដើម្បីបំពេញទុនឱ្យក្រុមហ៊ុនធានារ៉ាប់រងរបស់រដ្ឋប៉ុណ្ណោះ។ ទោះជាយ៉ាងនេះក្តី ទៅថ្ងៃមុខ បំណុលនេះ អាចនឹងរួមបញ្ចូលនូវសញ្ញាប័ណ្ណរដ្ឋដែលអាចជួញដូរបានផងដែរ ក្នុងករណីរាជរដ្ឋាភិបាលសម្រេចធ្វើការបោះផ្សាយ។

- **ការផ្តល់ឥណទានរបស់រដ្ឋ៖** សំដៅដល់ការឱ្យប្រាក់ដល់សហគ្រាសសាធារណៈ, គ្រឹះស្ថានសាធារណៈ, នីតិបុគ្គលសាធារណៈដទៃទៀត និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ខ្ចី ដោយប្រើប្រាស់ថវិការដ្ឋ ឬហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ក្នុងគោលដៅជំរុញកិច្ចអភិវឌ្ឍសេដ្ឋកិច្ច-សង្គម។

## H. Definitions

Terminologies used in this bulletin are defined as follows:

- **Public External Debt:** refers to the external debts of the government incurred under the applicable laws and excluding non-guaranteed debts. In Cambodia's current context, the public external debt comprises only concessional loans from bilateral and multilateral external development partners. However, this debt, in the future, would also include other instruments such as sovereign bonds in case of issuance decided by the RGC.

- **Public Domestic Debt:** refers to the internal debts of the government incurred under the applicable laws and excluding non-guaranteed debts. In Cambodia's current context, the public domestic debt comprises only non-marketable government bonds issued by the RGC to recapitalize its state-owned insurance companies. However, this debt, in the future, would also include marketable government bonds in case of issuance decided by the RGC.

- **Government Lending and On-lending:** refers to the credits provided by the government under government budget or development partners' financing to state-owned enterprises, public institutions, legal entities, and banking and financial institutions for the purpose of supporting socio-economic development.

- **ការខ្ចី៖** សំដៅដល់ទំហំឥណទានដែលរដ្ឋចុះកិច្ចព្រមព្រៀងជាមួយដៃគូអភិវឌ្ឍន៍។

- **Borrowing:** refers to the amount of loans that the government signed in the agreement with development partners.

- **ការដកសាច់ប្រាក់៖** សំដៅដល់សាច់ប្រាក់ដែលឥណទាយកបានអនុញ្ញាតឱ្យឥណទាយិក ដកយកមកប្រើប្រាស់ជាក់ស្តែង ក្នុងការអនុវត្តគម្រោង/កម្មវិធី។

- **Disbursement:** refers to proceeds or cash a creditor agreed with a debtor on the withdrawal for actual expenses in implementing a project / program.

- **សេវាបំណុល៖** សំដៅដល់ប្រាក់ដើម, ការប្រាក់, និងកម្រៃពាក់ព័ន្ធផ្សេងទៀត។

- **Debt Service:** refers to principal, interest, and other fees.

- **សន្និធិបំណុល៖** សំដៅដល់ទំហំបំណុលជាក់ស្តែងដែលឥណទាយិកមិនទាន់ទូទាត់ជូនឥណទាយក។ ជាទូទៅ សន្និធិបំណុល ស្មើនឹងការដកសាច់ប្រាក់សរុប ដកឱ្យ៖ ការបង្វែរសាច់ប្រាក់ទៅដៃគូអភិវឌ្ឍន៍វិញ និងការទូទាត់ប្រាក់ដើមសរុប។ ជាករណីពិសេស សម្រាប់កម្ពុជា សន្និធិបំណុលសាធារណៈក្រៅប្រទេស ស្មើនឹង៖ ការដកសាច់ប្រាក់សរុប ដកឱ្យ ការបង្វែរសាច់ប្រាក់ទៅដៃគូអភិវឌ្ឍន៍វិញ, ការទូទាត់ប្រាក់ដើមសរុប, និងបំណុលដែលបានលុបដោយដៃគូអភិវឌ្ឍន៍ បូកនឹង បំណុលចាស់ដែលបានចរចាដោះស្រាយរួចហើយកំពុងសង និងបំណុលចាស់ដែលកំពុងចរចាដោះស្រាយ។

- **Outstanding:** refers to actual amount of unpaid debts that the debtor has to pay to the creditor. Commonly, outstanding equals to the total disbursements minus: refund to creditors and total repaid principal. Uniquely, the outstanding for Cambodia's Public External Debt equals: total disbursement minus refund to creditors, total repaid principal, and cancelled debts by creditors plus rescheduled and under negotiated old debts.

- **បំណុលចាស់៖** សំដៅដល់បំណុលដែលបន្សល់ទុកដោយរដ្ឋាភិបាលជំនាន់មុន។ ក្នុងបរិការណ៍កម្ពុជា បំណុលចាស់ គឺជាបំណុលដែលបានកើតឡើងមុនឆ្នាំ១៩៩៣។ ភាគច្រើននៃបំណុលទាំងនេះ ត្រូវបានចរចាដោះស្រាយជាមួយដៃគូរួចរាល់ហើយ ក្នុងនោះ មួយចំនួនត្រូវបានទូទាត់សងរួចរាល់ជាស្ថាពរ និងមួយចំនួនកំពុងត្រូវបានទូទាត់តាមកម្មវិធីសងក្នុងកិច្ចព្រមព្រៀង។ ដោយឡែកចំពោះបំណុលចាស់ដែលនៅសេសសល់ បច្ចុប្បន្នរាជរដ្ឋាភិបាល បាននិងកំពុងខិតខំបន្តដោះស្រាយជាមួយដៃគូឱ្យបានជ្រះស្រឡះ។

- **Old Debts:** refers to legacy debts inherited from the previous governments. In Cambodia's context, old debts refer to ones incurred before 1993. Most old debts have been already resolved with partners; some of them were fully paid back while some others have been being repaid based on the rescheduling agreements. Concerning the remaining old debts, the RGC has been making the effort to find clear-cut resolutions with partners.

- **ឥណទាយក៖** សំដៅដល់ដៃគូអភិវឌ្ឍន៍ទ្វេភាគី និងពហុភាគី ដែលផ្តល់ឥណទានឱ្យរដ្ឋខ្ចី ដូចជា៖ ចិន, ជប៉ុន, សាធារណៈរដ្ឋកូរ៉េ, បារាំង, ធនាគារអភិវឌ្ឍន៍អាស៊ី, និងធនាគារពិភពលោក ជាដើម។

- **Creditor:** refers to both bilateral and multilateral development partners who provided loans to the RGC such as: China, Japan, Republic of Korea, France, ADB, and WB, etc.

- **ឥណទាយិក៖** សំដៅដល់សហគ្រាសសាធារណៈ, គ្រឹះស្ថានសាធារណៈ, នីតិបុគ្គលសាធារណៈដទៃទៀត, និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលទទួលបានឥណទានពីរដ្ឋ។

- **Debtor:** refers to state-owned enterprises, public institutions, legal entities, and banking and financial institutions, which receive loan/sub-loan from the government.

- **តម្លៃបច្ចុប្បន្ននៃបំណុល៖** សំដៅដល់ទំហំសន្និធិបំណុលក្រោយដកធាតុអំណោយ។ តាមបទដ្ឋានបច្ចេកទេសអន្តរជាតិ ក្នុងការគណនាអនុបាតបំណុល គេមិនប្រើតម្លៃចារឹកនៃបំណុលទេ គឺគេប្រើតម្លៃបច្ចុប្បន្ននៃបំណុល។ ចំពោះកម្ពុជាក៏ដូចគ្នាដែរ គឺត្រូវប្រើតម្លៃបច្ចុប្បន្ននៃបំណុល ព្រោះថា ឥណទានដែលរដ្ឋខ្ចីពីក្រៅប្រទេសទាំងអស់សុទ្ធសឹងជាឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់។

- **Present Value (PV) of Debts:** refers to the outstanding amount of debts after the deduction of grant element. According to international best practices, debt ratios are calculated by using the PV of debts instead of the Face Value. Similarly, this approach is also applied in Cambodia since all external loans are highly concessional.

- **ធាតុអំណោយ៖** សំដៅដល់ផលធៀបរវាង ១) ផលដកនៃតម្លៃចារឹករបស់ឥណទាន និងតម្លៃបច្ចុប្បន្ននៃការទូទាត់សេវាបំណុល និង ២) តម្លៃចារឹករបស់ឥណទាន។ ធាតុអំណោយ ត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការវាស់ស្ទង់កម្រិតសម្បទាននៃឥណទាន។

- **Grant Element:** refers to the proportion between 1) the difference between the Face Value of the loan and the PV of future debt service payments, and 2) the Face Value of the loan. Grant Element is used to measure the concessionality of a loan.

- **តម្លៃចារឹកនៃបំណុល៖** សំដៅដល់ទំហំសន្និធិបំណុលដែលពុំទាន់ដកធាតុអំណោយ។

- **Face Value of Debts:** refers to the outstanding amount of debts before the deduction of grant element.

- **ក្លឹបប៉ារីស៖** សំដៅដល់ក្រុមឥណទាយក ដែលបង្កើតឡើងក្នុងគោលបំណងផ្តល់ការអនុគ្រោះបំណុលដល់ឥណទាយិកដែលពុំមានលទ្ធភាពក្នុងការទូទាត់សងបំណុល។ បច្ចុប្បន្ន ក្លឹបប៉ារីស មានសមាជិកអចិន្ត្រៃយ៍ចំនួន ២០ ប្រទេស រួមមាន៖ អូស្ត្រាលី, អូទ្រីស, បែលហ្ស៊ិក, កាណាដា, ដាណឺម៉ាក, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, អៀរឡង់, អ៊ីស្រាអែល, អ៊ីតាលី, ជប៉ុន, ហូឡង់, ន័រវែស, រុស្ស៊ី, អេស្ប៉ាញ, ស៊ុយអែត, ស្វីស, ចក្រភពអង់គ្លេស, និងសហរដ្ឋអាមេរិក។

- **Paris Club**: is a group of creditor countries aiming at addressing old debts issues for debtor countries experiencing debt repayment difficulties. At present, the Paris Club is comprised of 20 permanent country members including: Australia, Austria, Belgium, Canada, Denmark, Finland, France, Germany, Ireland, Israel, Italy, Japan, Netherlands, Norway, Russian Federation, Spain, Sweden, Switzerland, UK, and USA.

- **ឥណប្រតិទាន៖** សំដៅដល់រយៈពេលត្រូវសងបំណុលសរុប ដោយគិតចាប់ពីពេលដែលកិច្ចព្រមព្រៀងឥណទាន ឬកិច្ចព្រមព្រៀងស្តីពីការផ្តល់ឥណទាន ចូលជាធរមាន រហូតដល់បំណុលត្រូវបានសងអស់។ ឥណ-

- **Maturity:** refers to the period from the date of signature of the loan to the last payment of the principal. Maturity is the sum of grace period

ប្រតិទាន ស្មើនឹងរយៈពេលអនុគ្រោះ បូកនឹងរយៈពេលសងដើម។

and repayment period.

- **រយៈពេលអនុគ្រោះ៖** សំដៅដល់រយៈពេលចន្លោះពីពេលដែលកិច្ចព្រមព្រៀងឥណទាន ឬកិច្ចព្រមព្រៀងស្តីពីការផ្តល់ឥណទានចូលជាធរមាន រហូតដល់ពេលត្រូវសងប្រាក់ដើមដំបូង ដោយក្នុងរយៈពេលនោះ មានតែការប្រាក់ប៉ុណ្ណោះ ដែលត្រូវទូទាត់។

- **Grace Period:** refers to the period from the loan effective date to the first repayment of principal and only interest is charged during this period.

- **រយៈពេលមធ្យមដល់ឥណប្រតិទាន៖** សំដៅដល់រយៈពេលមធ្យមនៃការទូទាត់ប្រាក់ដើម គិតពីរយៈពេលជាក់លាក់ណាមួយ រហូតដល់ឥណប្រតិទាន។

- **Average Time to Maturity (ATM):** refers to the weighted average time of principal repayments int the portfolio, starting from a specific period to the maturity.

- **វិស័យហេដ្ឋារចនាសម្ព័ន្ធ** រួមមាន៖ ផ្លូវថ្នល់, ស្ពាន, ផ្លូវដែក, កំពង់ផែ, អាកាសយានដ្ឋាន, ប្រព័ន្ធធារាសាស្ត្រ, អគ្គិសនី, ការផ្គត់ផ្គង់ទឹកស្អាត, និងស្ថានីយ៍សម្អាតទឹកកខ្វក់។

- **Infrastructure** includes: roads, bridges, railways, ports, airports, irrigation systems, electricity, water supply, and waste water treatment.

- **វិស័យអាទិភាពផ្សេងទៀត** រួមមាន៖ សេដ្ឋកិច្ច, ហិរញ្ញវត្ថុ, ទេសចរណ៍, អប់រំ, សេវាសាធារណៈ, សុខាភិបាល, និងដីធ្លី។

- **Other priority sectors** include: economy, finance, tourism, education, public services, health, and land management.

# ជំពូក ២

# តារាងស្ថិតិ

# Chapter II

# Statistical Tables

តារាងទី១ / Table 1:

**អត្រាប្តូរប្រាក់ / Exchange Rates**

ធៀបនឹងដុល្លារអាមេរិក / Other Currencies vs. USD

| រូបិយប័ណ្ណ / Currency | 31-12-15 | 31-12-16 | 30-06-17 |
|---|---|---|---|
| KHR | 4,050 | 4,037 | 4,086 |
| CNY | 6.459330 | 6.924528 | 6.753719 |
| EUR | 0.909908 | 0.941794 | 0.870195 |
| JPY | 119.875684 | 115.855933 | 111.547912 |
| KRW | 1,170.520231 | 1,201.488095 | 1,139.748954 |
| MYR | 4.269900 | 4.458310 | 4.269592 |
| SDR | 0.717449 | 0.742505 | 0.715524 |
| THB | 36.000000 | 35.725664 | 33.908714 |

តារាងទី២ / Table 2:

**សូចនាករបំណុល / Debt Indicators**

ជាភាគរយ / Percentage

**ក. សូចនាករគន្លឹះទាំង ០៥ / A- DSA Indicators**

| អនុបាត / Ratio | អនុបាតគោល / Threshold | 2015 | 2016 | 2017e |
|---|---|---|---|---|
| I. តម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស / PV of Public External Debt | | | | |
| - ធៀបនឹង ផសស / to GDP | 40 | 23.2 | 22.5 | 22.8 |
| - ធៀបនឹង ការនាំចេញ / to Exports | 150 | 33.5 | 31.6 | 30.8 |
| - ធៀបនឹង ចំណូលថវិកាជាតិ / to Revenue | 250 | 147.6 | 138.2 | 135.8 |
| II. សេវាបំណុល / Debt Service | | | | |
| - ធៀបនឹង ការនាំចេញ / to Exports | 20 | 1.3 | 1.4 | 1.6 |
| - ធៀបនឹង ចំណូលថវិកាជាតិ / to Revenue | 20 | 5.7 | 6.1 | 7.0 |

កំណត់សម្គាល់ / Technical Notes:

*1- អនុបាតគោលទាំងនេះ គឺកំណត់ដោយមូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោក /*

*The thresholds are defined by the IMF and World Bank for the medium policy countries.*

*2- ទិន្នន័យទាំងអស់ផ្អែកលើការវិភាគចីរភាពបំណុលតាមបទដ្ឋានបច្ចេកទេសអន្តរជាតិរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ /*

*All the figures here are based on DSA exercise which is done by MEF.*

**ខ. សូចនាករគន្លឹះផ្សេងទៀត / B- Other Key Indicators**

| អនុបាត / Ratio | 2015 | 2016 | 2017e |
|---|---|---|---|
| - សេវាបំណុល ធៀបនឹង ចំណាយសរុប / Debt Service to Total Expenditure | 3.6% | 4.3% | 4.3% |
| + ប្រាក់ដើម ធៀបនឹង ចំណាយមូលធន / Principal to Capital Expenditure | 6.0% | 8.0% | 8.9% |
| + ការប្រាក់ និងកម្រៃផ្សេងៗ ធៀបនឹង ចំណាយចរន្ត / Interest and Other Fees to Current Expenditure | 2.3% | 2.5% | 2.1% |
| - ការខ្ចីជាក់ស្តែង ធៀបនឹង ផសស / Actual Borrowing to GDP | 4.2% | 4.2% | 4.5% |
| - ការដកសាច់ប្រាក់ ធៀបនឹង ឱនភាពថវិកាសរុប / Disbursement to Overall Deficit | 81.6% | 84.8% | 103.6% |

តារាងទី៣ / Table 3:

## សូចនាករថ្លៃ និងហានិភ័យ / Cost - Risk Indicators

| សូចនាករ / Indicator | 2015 | 2016 | ឆមាសទី១ / S1 2017 |
|---|---|---|---|
| សមាសភាគបំណុលសាធារណៈជារូបិយប័ណ្ណបរទេស / Share of Foreign Currency in Total Public Debt | 99.95% | 99.95% | 99.96% |
| រយៈពេលមធ្យមដល់ឥណប្រតិទាន (ឆ្នាំ) / Average Time to Maturity - "ATM" (Year) | 10.75 | 10.45 | 10.83 |
| អត្រាការប្រាក់មធ្យម / Weighted Average Interest Rate | 1.03% | 1.03% | 0.83% |
| ឥណប្រតិទានមធ្យម (ឆ្នាំ) / Weighted Average Maturity (Year) | 29.31 | 29.30 | 30.94 |
| រយៈពេលអនុគ្រោះមធ្យម (ឆ្នាំ) / Weighted Average Grace Period (Year) | 8.62 | 8.58 | 9.06 |
| ធាតុអំណោយមធ្យម / Weighted Average Grant Element | 48.32% | 48.32% | 52.10% |

តារាងទី៤ / Table 4:

**ការខ្ចី, ការដកសាច់ប្រាក់, ការទូទាត់សេវាបំណុល, និងសន្និធិបំណុល** / Borrowing, Disbursement, Debt Service Payment, and Outstanding

ឯកតា÷ ប៊ីលានរៀល, លានដុល្លារអាមេរិក / Unit: KHR Billion, USD Million

| បរិយាយ / Description | 2015 | | 2016 | | ឆមាសទី១ / S1 2017 | | សរុបត្រឹមឆមាសទី១ / Accu. as of S1 2017 | | |
|---|---|---|---|---|---|---|---|---|---|
| | KHR | USD | KHR | USD | KHR | USD | KHR | USD | % |
| **I. ការខ្ចី / Borrowing** | **3,152.54** | **778.40** | **3,416.90** | **846.39** | **2,991.21** | **732.06** | **38,061.28** | **9,315.05** | ***100.00%*** |
| - ក្នុងប្រទេស / Domestic | - | - | - | - | - | - | 80.84 | 19.78 | *0.21%* |
| - ក្រៅប្រទេស / External | 3,152.54 | 778.40 | 3,416.90 | 846.39 | 2,991.21 | 732.06 | 37,980.44 | 9,295.26 | *99.79%* |
| **II. ការដកសាច់ប្រាក់ / Disbursement** | **2,416.91** | **595.30** | **2,205.77** | **543.31** | **1,266.77** | **313.28** | **25,597.56** | **6,264.70** | ***100.00%*** |
| - ក្នុងប្រទេស / Domestic | - | - | - | - | - | - | 80.84 | 19.78 | *0.32%* |
| - ក្រៅប្រទេស / External | 2,416.91 | 595.30 | 2,205.77 | 543.31 | 1,266.77 | 313.28 | 25,516.72 | 6,244.92 | *99.68%* |
| **III. ការទូទាត់សេវាបំណុល / Debt Service Payment** | **554.81** | **136.72** | **754.44** | **186.11** | **403.63** | **100.02** | **4,129.86** | **1,010.73** | ***100.00%*** |
| **1. ក្នុងប្រទេស / Domestic** | **1.83** | **0.45** | **0.35** | **0.09** | **0.17** | **0.04** | **68.33** | **16.72** | ***1.65%*** |
| - ប្រាក់ដើម / Principal | 1.60 | 0.40 | - | - | - | - | 56.50 | 13.83 | *82.68%* |
| - ការប្រាក់ និងកម្រៃផ្សេងៗ / Interest and Other Fees | 0.23 | 0.06 | 0.35 | 0.09 | 0.17 | 0.04 | 11.83 | 2.90 | *17.32%* |
| **2. ក្រៅប្រទេស / External [(1)]** | **552.98** | **136.27** | **754.10** | **186.03** | **403.46** | **99.98** | **4,061.53** | **994.01** | ***98.35%*** |
| - ប្រាក់ដើម / Principal | 327.76 | 80.94 | 463.05 | 114.26 | 255.11 | 63.17 | 2,296.43 | 562.02 | *56.54%* |
| - ការប្រាក់ និងកម្រៃផ្សេងៗ / Interest and Other Fees | 225.22 | 55.32 | 291.05 | 71.77 | 148.35 | 36.81 | 1,765.10 | 431.99 | *43.46%* |
| **IV. សន្និធិបំណុល / Outstanding [(2)]** | **22,886.40** | **5,650.96** | **23,672.21** | **5,863.78** | **25,480.08** | **6,235.95** | **25,480.08** | **6,235.95** | ***100.00%*** |
| - ក្នុងប្រទេស / Domestic | 11.18 | 2.76 | 11.18 | 2.74 | 11.18 | 2.74 | 11.18 | 2.74 | *0.04%* |
| - ក្រៅប្រទេស / External | 22,875.22 | 5,648.20 | 23,661.03 | 5,861.04 | 25,468.90 | 6,233.21 | 25,468.90 | 6,233.21 | *99.96%* |

**កំណត់សម្គាល់ / Technical Notes:**

*(1)- គិតបញ្ចូលទាំងការទូទាត់សេវាបំណុលនៃបំណុលចាស់ដែលបានដោះស្រាយរួច / Rescheduled old debts are included in the debt service payment.*

